00790082

E172/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 03 / 2012
ម៉ោង (Time/Heure) : 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

សំណុំរឿងលេខៈ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007/ECCC/TC**

ចំណាត់ថ្នាក់ឯកសារ៖ **សាធារណៈ**

# ដីកាបង្គាប់ឲ្យនាំខ្លួន

យើងចៅក្រម **និល ណុន** ជាប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

**យោង** អនុស្សរណៈដែលបានចេញដោយចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ E172) ដីកាកោះហៅសាក្សីដែលបានកែប្រែ (ឯកសារ E172/6) និងដីកាបង្គាប់ឲ្យនាំខ្លួន (ឯកសារ E172/7)។

មន្ទីរឃុំឃាំង អ.វ.ត.ក
ចូល
លេខ 071 [illegible]
ថ្ងៃទី 16 ខែ មិនា ឆ្នាំ 2012
ម៉ោង 2:10

## <u>បង្គាប់មក</u>

លោកប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឲ្យនាំខ្លួនឈ្មោះ កាំង ហ្កេកអ៊ាវ ហៅឌុច ភេទ ប្រុស កើតនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ប្រទេសកម្ពុជា មកកាន់សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី **២០ ខែ មិនា ឆ្នាំ ២០១២ នៅម៉ោង ៨.៣០ នាទី ព្រឹក** ដើម្បីស្តាប់ចម្លើយ និងបង្គាប់ឲ្យនាំគាត់ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក វិញ នៅពេលដែលការផ្តល់សក្ខីកម្មរបស់គាត់ត្រូវបានផ្អាក។ ការអនុវត្តដូច្នេះត្រូវបន្តធ្វើរហូតទាល់តែការផ្តល់សក្ខីកម្មរបស់គាត់ត្រូវបានបញ្ចប់ ដីកាបង្គាប់ឲ្យនាំខ្លួនឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ២០១២ នឹងត្រូវបាត់អានុភាព ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ២០១២
**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

**និល ណុន**

០០២/១៩ កញ្ញា ២០០៧/អវតក/អជសង

E172/8

# **ការទទួលស្គាល់អំពីការទទួលលិខិត**

យើង ខៀវ ចយ ជាប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពិតជាបានទទួលដីកាបង្គាប់ឲ្យនាំខ្លួនទណ្ឌិតមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពិតប្រាកដមែន។ យើងនឹងចាត់បញ្ជូនឈ្មោះនេះឲ្យបានទាន់ពេលវេលា និងទៀងទាត់តាមកាលកំណត់របស់អង្គជំនុំជម្រះសាលាដំបូង។

ភ្នំពេញថ្ងៃទី 16 ខែមិនា ឆ្នាំ ២០១១

ប្រធានមន្ទីរឃុំឃាំង

ខៀវ_ចយ